**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**

# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍សង្ខេបពិធីបិទសន្និបាតបូកសរុប លទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ

**ថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤**

**នៅទីស្តីការក្រសួងផែនការ**

- សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ជាទីគោរព
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត តំណាងដៃគូអភិវឌ្ឍ ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា ជាទីរាប់អាន!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាអនេកប្បការ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងផែនការ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត អញ្ជើញចូលរួមជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ នាពេលនេះ។ ខ្ញុំសូមស្វាគមន៍ និងសូមថ្លែងអំណរគុណចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត, លោក លោកស្រី តំណាងដៃគូអភិវឌ្ឍ ភ្ញៀវកិត្តយស និងសមាជិក សមាជិកា**នៃអង្គសន្និបាតទាំងមូលដែលបានឆ្លៀតពេលដ៏មានតម្លៃអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ នាពេលនេះ។

ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** និងអង្គសន្និបាតទាំងមូលមេត្តាជ្រាបថា ក្រសួងផែនការ បានរៀបចំសន្និបាតប្រចាំឆ្នាំរបស់ខ្លួនចុងក្រោយនៅឆ្នាំ២០០៨ ដោយបានខកខានរៀបចំចាប់ពីឆ្នាំ២០០៩មក ដោយសារមូលហេតុថវិកានិងពេលវេលា។ ថ្ងៃនេះ ពិតជាកិត្តិយសណាស់ ដែល

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានផ្តល់ឱកាសដល់ក្រសួងផែនការរៀបចំសន្និបាតបូកសរុបលទ្ធផល និងទិសដៅការងារប្រចាំឆ្នាំរបស់ខ្លួនឡើងវិញ ដែលនេះពិតជាឱកាសដ៏កម្រសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងផែនការ ទាំងនៅថ្នាក់កណ្តាល និងនៅថ្នាក់រាជធានី ខេត្ត បានជួបជុំគ្នា។ ក្នុងដំណើរការសន្និបាតរយៈពេលមួយថ្ងៃកន្លះនេះ តាមអង្គភាពជំនាញនីមួយៗ បានធ្វើបង្ហាញអំពីសមិទ្ធផលធំៗ និងបញ្ហាប្រឈមរួមទាំងសំណូមពរមួយចំនួន ប៉ុន្តែដោយសារ ពេលវេលាមានកំណត់ ខ្ញុំបាទស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចធិបតី** និងអង្គពិធីទាំងមូល ដើម្បីជម្រាបជូននិងធ្វើរបាយការណ៍អំពីលទ្ធផលការងារធំៗ ឆ្នាំ២០២៣ តាមអង្គភាពជំនាញនីមួយៗដែលមានខ្លឹមសារសង្ខេបដូចតទៅ៖

## I- សមិទ្ធផលការងារធំៗឆ្នាំ២០២៣

### ១- អគ្គនាយកដ្ឋានកិច្ចការទូទៅ

អគ្គនាយកដ្ឋានកិច្ចការទូទៅ ជាអង្គភាពសម្របសម្រួលថ្នាក់កណ្តាលលើការងារគ្រប់គ្រងបុគ្គលិករដ្ឋបាលទូទៅ ហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងអាណត្តិទី៧ នៃរដ្ឋសភានេះ ក្រសួងផែនការបាននិងកំពុងពង្រឹងការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការគ្រប់គ្រងវត្តមានមន្ត្រីរាជការ ដើម្បីជាមូលដ្ឋានក្នុងការកំណត់ពីមន្ត្រីសកម្ម អសកម្ម និងមន្ត្រីដែលមិនមកធ្វើការ ឬយកពេលម៉ោងរាជការទៅធ្វើការនៅកន្លែងផ្សេង។ ការងារកំណែទម្រង់ហិរញ្ញវត្ថុ ក្រសួងផែនការបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការពង្រឹងអង្គភាពថវិកាតាមអគ្គនាយកដ្ឋានជំនាញ ដើម្បីគ្រប់គ្រងការចំណាយឱ្យមានប្រសិទ្ធភាព និងការត្រៀមក្លាយខ្លួនទៅ ជាអង្គភាពថវិកាពេញពេញតាមរបៀបវារៈកំណែទម្រង់ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ក្រសួងផែនការ បាននិងកំពុងពង្រឹងការងារកិច្ចសហប្រត្តិបត្តិការអន្តរជាតិជាមួយនឹងបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកជាទ្វេភាគី និងជាពហុភាគី និងបានគិតគូបង្កើតយន្តការសម្របសម្រួលការងារសហប្រតិបត្តិការត្បូង-ត្បូង និងត្រីកោណ។ ជាមួយគ្នានេះដែរ ក្រសួងផែនការ ក៏បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលទិន្នន័យ និងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួងផែនការ ដើម្បីប្រមូលផ្តុំគ្រប់គ្រងលើទិន្នន័យច្រើនប្រភេទកំពុងនៅរាយប៉ាយគ្នា ដែលកំពុងផ្ទុក និងបង្ហោះដោយក្រុមហ៊ុនឯកជន និងស្ថាប័នដ៏ទៃ មានដូចជា ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, ទិន្នន័យមូលដ្ឋានថ្នាក់ក្រោមជាតិ, ទិន្នន័យជំរឿន, អង្កេត, CAMSTAT ជាដើម។ បច្ចុប្បន្នកំពុងដំណើរការនិងបង្ហោះនៅលើថ្នាលសកលរបស់អង្គការសហប្រជាជាតិ និងទិន្នន័យមួយចំនួនទៀត ដូចជា ជំរឿន អង្កេតផ្ទុកនៅម៉ាស៊ីនមេតូចៗតាមអង្គភាពនីមួយៗ។

### ២- អគ្គនាយកដ្ឋានផែនការ

អគ្គនាយកដ្ឋានផែនការ ជាអង្គភាពជំនាញថ្នាក់កណ្តាល ទទួលខុសត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល, ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត, ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, ការងារលើកកម្ពស់អាហារូបត្ថម្ភ រួមមាន៖ កម្មវិធីលុបបំបាត់ជាតិអ៊ីយ៉ូត និងបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ, ការងារផែនការនៅថ្នាក់ក្រោមជាតិ, ការងារវាស់វែងភាពក្រីក្ររបស់ប្រជាជន និងកុមារកម្ពុជា។

ការងារទាំងអស់នេះ សុទ្ធតែមានសារៈសំខាន់ក្នុងការព្យាករ និងការកំណត់អំពីទិសដៅសម្រាប់ អភិវឌ្ឍ សង្គម-សេដ្ឋកិច្ចកម្ពុជា ផ្សារភ្ជាប់នឹងសេដ្ឋកិច្ចសកលលោក ជាពិសេសផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ត្រូវបានរៀបចំឡើង សម្រាប់អនុវត្តគោលនយោបាយអាទិភាពជាតិ ដែលមានចែងក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងជាធាតុចូលសម្រាប់ការរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេល មធ្យម ក្របខ័ណ្ឌចំណាយថវិការយៈពេល មធ្យម និងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា និងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត គឺជាឯកសារសំខាន់សម្រាប់អនុវត្តគោលដៅ និងអនុសញ្ញាសាកលដែលកម្ពុជាបានផ្តល់សច្ចាប័ន។ អត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានទទួលស្គាល់ និងប្រើប្រាស់ទូលំទូលាយសម្រាប់វិស័យគាំពារសង្គម និងសុខភាព ដែលបច្ចុប្បន្ននេះមានគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យមានប្រមាណ ១,២លានគ្រួសារ ដែលគ្រប ដណ្តប់ប្រជាជនប្រមាណ ៥លាននាក់ កំពុងទទួលបានការគាំទ្រពីរាជរដ្ឋាភិបាលតាមរយៈកម្មវិធីគាំពារសង្គម។

### ៣- វិទ្យាស្ថានជាតិស្ថិតិ

វិទ្យាស្ថានជាតិស្ថិតិ ជាអង្គភាពជំនាញថ្នាក់កណ្តាលដែលទទួលខុសត្រូវក្នុងការប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងទិន្នន័យស្ថិតផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា ដែលអនុលោមតាមច្បាប់ស្តីពីស្ថិតិ "**វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានតួនាទី និងភារកិច្ចក្នុងការកសាងគោលនយោបាយស្ថិតិផ្លូវការ ក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្រសួង ស្ថាប័ន។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ**"។

ក្នុងឆ្នាំ២០២៣នេះ វិទ្យាស្ថានជាតិស្ថិតិ បានដឹកនាំធ្វើជំរឿន និងអង្កេតធំៗមួយចំនួន រួមមាន៖ ជំរឿនកសិកម្មនៅកម្ពុជាឆ្នាំ២០២៣, អង្កេតកសិកម្មនៅកម្ពុជាប្រចាំឆ្នាំ២០២៣, អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០២៣, អង្កេតនវានុវត្តន៍សម្រាប់ខេត្តបន្ទាយមានជ័យ កំពង់ចាម និងខេត្តស្វាយរៀង ឆ្នាំ២០២៣, អង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ សម្រាប់ខេត្តកំពត និងខេត្តកែប, អង្កេតស្តីពីការពិនិត្យបង្គន់អនាម័យឆ្នាំ២០២៣។ ការងារគណនេយ្យជាតិ និងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ គឺមានសារៈ សំខាន់ក្នុងការគណនា វិភាគ និងព្យាករអំពីសេដ្ឋកិច្ចកម្ពុជា ជាមួយគ្នានេះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយមានការសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគោរពស្នើសុំគោលការណ៍ ប្តូរឆ្នាំគោលគណនេយ្យជាតិ ពីឆ្នាំគោលឆ្នាំ២០០០ មកឆ្នាំគោលឆ្នាំ២០១៤ ទទួលបានការឯកភាព ពី**សម្តេចធិបតី នាយករដ្ឋមន្ត្រី** ប្រកបដោយជោគជ័យ។ ថ្មីៗនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់របាយការណ៍ថ្នាក់ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២២ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

## ៤- អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍

អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍ ជាអង្គភាពជំនាញថ្នាក់កណ្ដាលដែលទទួលខុសត្រូវលើការងារពាក់ព័ន្ធនឹងប្រជាជន និងអភិវឌ្ឍន៍។ ការងារស្នូលជាអាទិភាពរបស់អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍ គឺការងាររៀបចំគោលនយោបាយជាតិប្រជាជននិងតាមដានត្រួតពិនិត្យ និងវាយតម្លៃ, កម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍, ការងារផ្សព្វផ្សាយ, ការងារបណ្ដុះបណ្ដាល, ការងារអភិវឌ្ឍន៍សហគមន៍, ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍, និងការងារកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យប្រជាជន និងអភិវឌ្ឍន៍។

រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលនយោបាយជាតិប្រជាជនលើកដំបូងនៅឆ្នាំ២០០៣ ដែលស្របទៅតាមកតិកាសញ្ញាអន្តរជាតិនានា រួមទាំងផែនការសកម្មភាព នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជន និងអភិវឌ្ឍន៍ឆ្នាំ១៩៩៤ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០០០។ នៅឆ្នាំ២០១៦ **គោលនយោបាយជាតិប្រជាជន** ត្រូវបានធ្វើបច្ចុប្បន្នភាពទៅជា **គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០** ដែលមានលក្ខណៈគ្របដណ្ដប់គ្រប់ជ្រុងជ្រោយ និងទំនាក់ទំនងពហុវិស័យរវាងបញ្ហាប្រជាជន និងការអភិវឌ្ឍ។ គោលបំណងរួមនៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ គឺឈរលើគោលការណ៍ផ្ដល់សិទ្ធិជាមូលដ្ឋានដល់គូស្វាមីភរិយា និងបុគ្គលទាំងអស់ក្នុងការសម្រេចចិត្តដោយសេរីនិងដោយទទួលខុសត្រូវលើចំនួនកូននិងការពន្យារកំណើត ហើយរាជរដ្ឋាភិបាលផ្ដល់លទ្ធភាពឱ្យពួកគាត់ទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយ ដើម្បីធ្វើការសម្រេចចិត្តឮនេះ។ ការរៀបចំ**ក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា និងផែនការសកម្មភាព ២០២៤-២០៣០៖ តាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្ដីពីប្រជាជន និងអភិវឌ្ឍន៍** គឺដើម្បីបង្ហាញពីការប្ដេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមអនុវត្តអនុសញ្ញា និងសេចក្ដីសម្រេចនានារបស់អង្គការសហប្រជាជាតិ។ ថ្មីៗនេះ ក្នុងការវាយតម្លៃស្ដីពីអាត្លាសគោលនយោបាយពន្យារកំណើត សម្រាប់តំបន់អាស៊ីនិងបាស៊ីហ្វិកឆ្នាំ២០២៣ (Contraception Policy ATLAS Asia-Pacific, 2023)" ប្រទេសកម្ពុជាបានស្ថិតក្នុងលំដាប់ប្រទេសដែលបានអនុវត្តល្អប្រសើរ (Best Performing Country) ដែលស្ថិតក្នុងលំដាប់កំពូលនៃតារាង (ចំណាត់ថ្នាក់លេខ១) ដោយទទួលបានពិន្ទុ៩០,១% ខ្ពស់ជាងបណ្ដាប្រទេសជាង៤០នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ ការងារចងក្រង និងគ្រប់គ្រងទិន្នន័យសហគមន៍ រួមទាំងទិន្នន័យសហគមន៍ជនជាតិដើមភាគតិច គឺជាការងារអាទិភាព ដើម្បីបង្កើតជាមូលដ្ឋានទិន្នន័យសហគមន៍ កម្ពុជា (Cambodia Community Database) ដែលមានគុណភាពសម្រាប់ជាប្រយោជន៍ដល់អ្នករៀបចំ គោលនយោបាយ ផែនការ និងអ្នកសិក្សាស្រាវជ្រាវ។

## ៥- សាលាជាតិជាតិផែនការ និងស្ថិតិ

សាលាជាតិជាតិផែនការ និងស្ថិតិ ត្រូវបានរាជរដ្ឋាភិបាល ដំឡើងកម្រិតពីមជ្ឈមណ្ឌលបណ្ដុះ បណ្ដាលផែនការ-ស្ថិតិ (ដែលមានសិទ្ធិបណ្ដុះបណ្ដាលត្រឹមកម្រិតមធ្យមលើជំនាញផែនការ និងស្ថិតិ) ទៅជាសាលាជាតិផែនការ និងស្ថិតិ ដែលមានសិទ្ធិបណ្ដុះបណ្ដាលដល់កម្រិតឧត្តម សុក្រឹតការ និងវិក្រឹតការ ក្នុងវិស័យផែនការ និងស្ថិតិ លើជំនាញផែនការអភិវឌ្ឍន៍ ស្ថិតិអនុវត្តន៍ ស្ថិតិប្រជាសាស្ត្រ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃ និងជំនាញពាក់ព័ន្ធផ្សេងទៀតតាមតម្រូវការជាក់ស្ដែង។ សាលាជាតិផែនការ និងស្ថិតិ មានតួនាទីនិងភារកិច្ចបណ្ដុះ បណ្ដាលធនធានមនុស្ស ដើម្បីបំពេញឱ្យការខ្វះខាតជំនាញក្នុងវិស័យផែនការ និងស្ថិតិ ដែល

កន្លងមក ជំនាញក្នុងវិស័យនេះមានកម្រិតទាប និងបរិមាណតិច មិនអាចឆ្លើយតបបានតាមតម្រូវការរីកចម្រើននៃប្រទេសជាតិ ការកែទម្រង់រដ្ឋបាលសាធារណៈ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្នសាលាជាតិជាតិផែនការ និងស្ថិតិ បាននិងកំពុងបណ្តុះបណ្តាលនិស្សិត និងមន្ត្រីរាជការសរុបចំនួន **៥៨៣នាក់ (ស្ត្រី១៣២នាក់ និងប្រុស៤៥១នាក់)** ដែលក្នុងនោះមន្ត្រីរាជការសិក្សាកម្រិតបរិញ្ញាបត្រ និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់លើជំនាញផែនការអភិវឌ្ឍន៍ ស្ថិតិអនុវត្ត ស្ថិតិប្រជាសាស្ត្រ និងតាមដានត្រួតពិនិត្យ និងវាយតម្លៃ សរុបចំនួន **៤៥២នាក់**។

## ៦- ការងារថ្នាក់ក្រោមជាតិ

មន្ទីរផែនការរាជធានី ខេត្ត ជាអង្គភាពជំនាញថ្នាក់ក្រោមជាតិដែលធ្វើការងារក្នុងនាមក្រសួងផែនការនៅថ្នាក់ក្រោមជាតិផង និងធ្វើជាសេនាធិការជូនគណៈអភិបាលរាជធានី ខេត្តផង រួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១។ ការងារសំខាន់ៗដែលមន្ទីរផែនការរាជធានី ខេត្ត បាន និងកំពុងអនុវត្ត រួមមាន៖ ការផ្តល់បច្ចេកទេស និងសម្របសម្រួល ការរៀបចំផែនការអភិវឌ្ឍន៍ ប្រាំឆ្នាំរាជធានី/ខេត្ត, កម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ជាពិសេសការអនុវត្តភារកិច្ចក្នុងតួនាទីជាសមាជិកអចិន្ត្រៃយ៍ក្រុមការងាររៀបចំផែនការ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី/ខេត្ត, ការគ្រប់គ្រងសម្របសម្រួលដំណើរការប្រមូលទិន្នន័យមូលដ្ឋានភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក, ការរៀបចំជាឯកសារព័ត៌មានស្ថានភាព និងឯកសារពិន្ទុវិស័យឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ រាជធានី ខេត្ត សម្រាប់ធ្វើជាឧបករណ៍បម្រើដល់ការងារកសាងផែនការគ្រប់វិស័យ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ការសម្របសម្រួលអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅតាមរាជធានី ខេត្ត, ការងារតាមដានត្រួតពិនិត្យការអនុវត្តគម្រោងថ្នាក់ក្រោមជាតិ, ការងារជំរឿននានា ជាពិសេស ជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣, ការបញ្ចូលទិន្នន័យជំរឿនកសិកម្មព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៣ នៅតាមរាជធានី ខេត្ត, ការចូលរួមធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា, ការងារស្រង់តម្លៃ ទំនិញទីផ្សារ, ការប្រមូលទិន្នន័យរៀបចំផលិតផលក្នុងស្រុកសរុបរាជធានី ខេត្ត, ការងារប្រជាជននិងអភិវឌ្ឍន៍, និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលនៅថ្នាក់រាជធានី ខេត្ត។

ខ្ញុំសូមឆ្លៀតយកឱកាសនេះដែរ ជម្រាបជូន **សម្តេចបវរធិបតីនាយករដ្ឋមន្ត្រី** និងអង្គសន្និបាតមេត្តាជ្រាបថា កម្ពុជា ត្រូវបានចាត់បញ្ចូលជាក្រុមប្រទេសអភិវឌ្ឍតិចតួចនៅឆ្នាំ១៩៩១។ ប្រទេសអភិវឌ្ឍតិចតួចមួយ ដែលអាចចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចបាន លុះត្រាឆ្លងការពិនិត្យបីឆ្នាំម្តង (Triennial Review) ចំនួនពីរដងជាប់ៗគ្នាដោយជោគជ័យ ដែលក្នុងនោះមានការវាយតម្លៃអំពីការបំពេញបាននូវ លក្ខណៈវិនិច្ឆ័យចំនួនបី គឺ (១).ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ (Gross National Income Per Capita – GNI Per Capita) ត្រូវស្មើឬធំជាង ១ ២២២ដុល្លារអាម៉េរិក (២).សន្ទស្សន៍ទ្រព្យធនមនុស្ស (Human Assets Index – HAI) ត្រូវស្មើឬធំជាង ៦៦ពិន្ទុ និង(៣).សន្ទស្សន៍ងាយរងគ្រោះសេដ្ឋកិច្ចនិង បរិស្ថាន (Economic and Environment Vulnerable Index – EVI) ត្រូវស្មើឬតូចជាង៣២ពិន្ទុ។ គណៈ កម្មាធិការគោលនយោបាយអភិវឌ្ឍន៍ (Committee for Development Policy – CDP) របស់អង្គការ សហប្រជាជាតិមានភារកិច្ចពិនិត្យ

លក្ខណៈវិនិច្ឆ័យទាំងបីខាងលើ។ កម្ពុជា បានបំពេញបាននូវលក្ខណៈវិនិច្ឆ័យទាំងបីជាលើកទីមួយនៅឆ្នាំ២០២១ និងលើកទីពីរនៅឆ្នាំ២០២៤ ដែលនៅលើកទី២ មានរួមបញ្ចូល នូវការវាយតម្លៃអំពីភាពងាយរងហានិភ័យ ដោយសារការចាកចេញ សូចនាករបន្ថែមជាច្រើន និងការវាយ តម្លៃការចាកចេញ។ កាលពីដើមខែមីនា ឆ្នាំ២០១៤ គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍បានជម្រាបមករាជរដ្ឋាភិបាលកម្ពុជាថា គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍ បានបោះឆ្នោតឱ្យកម្ពុជាចាកចេញពី ចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចក្នុងរយៈពេលប្រាំឆ្នាំតាមសំណើរបស់កម្ពុជា ហើយគណៈ
កម្មាធិការគោលនយោបាយអភិវឌ្ឍន៍ បានធ្វើសំណើ ទៅក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចសហប្រជាជាតិ (ECOSOC) ដើម្បីប្រជុំពិនិត្យនិងផ្តល់ការគាំទ្រនៅខែមិថុនា ឆ្នាំ២០២៤ មុននឹងផ្ញើជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិ ដែលអាចនឹងដំណើរការនាខែវិច្ឆិកា ឆ្នាំ២០២៤។ ក្នុងន័យនេះ ប្រសិនបើមហាសន្និបាតរបស់អង្គការសហប្រជាជាតិ បោះឆ្នោតគាំទ្រ តាមសំណើរបស់កម្ពុជា គឺមានន័យថា កម្ពុជានឹងចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួចជាផ្លូវការ នៅឆ្នាំ២០២៩។ ក្នុងរយៈពេលនៃការត្រៀមចាកចេញនេះ កម្ពុជាត្រូវរៀបចំយុទ្ធសាស្ត្រអន្តរកាលដោយរលូន (Smooth Transition Strategy) សម្រាប់អនុវត្តក្រោយការចាកចេញ។

## II- បញ្ហាប្រឈម

ចំពោះបញ្ហាប្រឈម ខ្ញុំបាទសូមលើកយកតែបញ្ហាប្រឈមធំៗចំនួនបី៖

**ទី១-** ក្រសួងផែនការមានចំនួនមន្ត្រីបុគ្គលិកគ្រប់គ្រាន់ល្មមសម្រាប់បំពេញភារកិច្ចស្នូលតាមអង្គភាពជំនាញនីមួយៗ ប៉ុន្តែមន្ត្រីដែលមានសមត្ថភាពជំនាញខាងសរសេរគោលនយោបាយ ផែនការ និងវិភាគទិន្នន័យស៊ីជម្រៅ មានតិច ហើយមន្ត្រីទាំងនោះភាគច្រើនមានអាយុជិតចូលនិវត្តន៍។ រយៈពេលកន្លងមក ក្រសួងផែនការ បានបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាលជាច្រើន ទាំងនៅក្នុងស្រុក ទាំងនៅបរទេស ប៉ុន្តែពេលត្រឡប់ មកវិញពួកគាត់មួយចំនួនបានផ្ទេរចេញទៅស្ថាប័នផ្សេង និងចូលនិវត្តន៍។

**ទី២-** ក្រសួងផែនការ មានទីតាំងល្អ ស្ថិតនៅចំកណ្តាលក្រុង ប៉ុន្តែមានសភាពតូច ពុំមានកន្លែងសម្រាប់ពង្រីកបន្ថែម ដើម្បីបម្រើនូវតម្រូវការការងាររបស់មន្ត្រី បុគ្គលិក ទាំងបន្ទប់ធ្វើការ និងចំណតរថយន្ត និងម៉ូតូ។

**ទី៣-** សាលាជាតិផែនការនិងស្ថិតិ មានទីតាំងដីសមរម្យល្មមនាពេលបច្ចុប្បន្ន ប៉ុន្តែនៅខ្វះធនធានសិក្សា សៀវភៅសិក្សាគោល ធនធានគ្រូបង្រៀនជំនាញពេញម៉ោង ថវិកាសម្រាប់ការអភិវឌ្ឍអគារការិយាល័យ បណ្ណាល័យ បន្ទប់ពិសោធន៍ ហើយអាគារខ្លះមានស្ថានភាពចាស់។

## III- ទិសដៅធំៗសម្រាប់ឆ្នាំ២០២៤

**ទី១-** បន្តពង្រឹងការកែទម្រង់ការគ្រប់គ្រងបុគ្គលិក មន្ត្រីរាជការ តាមរយៈ ការគ្រប់វត្តមានម៉ត់ចត់, និងការបណ្តុះបណ្តាលសមត្ថភាពនិងធនធានមនុស្ស ទាំងជំនាញ ទាំងភាពជាអ្នកដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ។

**ទី២-** បញ្ចប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ដោយត្រូវសុំការឯកភាពពីគណៈរដ្ឋមន្ត្រី ទទួលការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ រដ្ឋសភា និងព្រឹទ្ធសភា និងការឡាយព្រះហស្តលេខាពីព្រះមហាក្សត្រលើព្រះរាជក្រម សម្រាប់ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ, រៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ២០២៦-២០២៨, ផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០២៣, បន្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រសម្រាប់បន្តគាំទ្រដល់គោលនយោបាយជាតិគាំពារសង្គម, បន្តការងារលើកកម្ពស់ អាហារូបត្ថម្ភ, ការងារផែនការនៅថ្នាក់ក្រោមជាតិ, និងការងារវាស់វែងភាពក្រីក្រនៅកម្ពុជា ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣។

**ទី៣-** រៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ២០២៤-២០២, រៀបចំនិងចុះអនុវត្តអង្កេតចន្លោះជំរឿននៃប្រជាជនកម្ពុជាឆ្នាំ២០២៤ និងអង្កេតប្រជាសាស្ត្រ និងសុខភាពឆ្នាំ២០២៤ រួមទាំងការប្រមូលទិន្នន័យប្រចាំឆ្នាំនូវទិន្នន័យអំពីសន្ទស្សន៍ថ្លៃ ទំនិញប្រើប្រាស់ និងថ្លៃអ្នកផលិត, រៀបចំការប្រមូលទិន្នន័យសម្រាប់ចងក្រងផលិតផលក្នុង ស្រុកសរុប, រៀបចំនិងពង្រីកថ្នាលទិន្នន័យធំ, ដឹកនាំអង្កេតនវានុវត្តន៍នៅតាមបណ្តាខេត្ត គោលដៅមួយចំនួន និងគណនានិងផ្សព្វផ្សាយលទ្ធផល។

**ទី៤-** បញ្ចប់ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា និងផែនការសកម្មភាព ២០២៤-២០៣០៖ តាមដានការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍ ដើម្បីស្នើសុំការឯកភាពពី**សម្តេចបវរធិបតី នាយករដ្ឋមន្ត្រី**, រៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០, រៀបចំផែនការសកម្មភាពដំណាក់កាលទី៤ (២០២៥-២០២៧) នៃគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០, និងបន្តចុះប្រមូលទិន្នន័យសហគមន៍ជនជាតិភាគតិចតាមខេត្តគោលដៅ។

**ទី៥-** រៀបចំយុទ្ធសាស្ត្រអន្តរកាលដោយរលូន ស្តីពីការចាកចេញរបស់កម្ពុជាពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច។

**ទី៦-** សាលាជាតិផែនការ និងស្ថិតិ នឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់, បង្កើតជំនាញវិទ្យាសាស្ត្រទិន្នន័យ និងជំនាញផ្សេងទៀត, និងរៀបចំវគ្គបណ្តុះបណ្តាលវិក្រឹតការនិងសុក្រឹតការដល់មន្ត្រីរាជការជាពិសេសមន្ត្រីបន្តវេនជាអ្នកគ្រប់គ្រងនិងជាអ្នកដឹកនាំ។

មុននឹងបញ្ចប់ ខ្ញុំបាទសូមគោរពសុំការអធ្យាស្រ័យដ៏ខ្ពង់ខ្ពស់ពី **សម្តេចបវរធិបតីនាយករដ្ឋមន្ត្រី** ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់នូវរាល់ចំណុចខ្វះខាតទាំងឡាយដែលកើតមានជាយថាហេតុ ដូចជាការទទួលបដិសណ្ឋាកិច្ច, ការផ្តល់ជូននូវឯកសារពាក់ព័ន្ធ, រួមទាំងបញ្ហាចំណតរថយន្តជាដើម។ មន្ត្រីរាជការ និងថ្នាក់ដឹកនាំ នៃក្រសួងផែនការ ពិតជាមានការលំបាកណាស់ អំពីទីតាំងចំណតរថយន្ត និងម៉ូតូក៏ដូចជាការិយាល័យធ្វើការ។ ក្រសួងផែនការ មានទីតាំងល្អ ស្ថិតនៅចំកណ្តាលក្រុងភ្នំពេញ ប៉ុន្តែមានទីតាំងតូចចង្អៀត ដែលមានការលំបាកក្នុងការពង្រីក។ ការតូញត្អែររបស់មន្ត្រីរាជការ ពិតបានជះឥទ្ធិពលមិនសូវល្អដល់អារម្មណ៍របស់ថ្នាក់ដឹកនាំ ក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពង្រឹងសមត្ថភាពជំនាញ

មន្ត្រីរាជការ និងពង្រឹងស្ថាប័ន។ ក្នុងន័យនេះ ខ្ញុំបាទមិនមានបំណងត្អូញត្អែរ និងដាក់បន្ទុកបន្ថែមដល់ **សម្តេចបវរធិបតីនាយករដ្ឋមន្ត្រី** ទេនេះ គ្រាន់តែជាការគិតគូរសម្រាប់អនាគត ក្នុងករណីដែលរាជរដ្ឋាភិបាល មានលទ្ធភាពពង្រីកទីតាំងរដ្ឋបាលសាធារណៈ ខ្ញុំសូមគោរពស្នើសុំ **សម្តេចធិបតី** មេត្តាគិតគូរដល់មន្ត្រី ក្រសួងផែនការជាបឋម ព្រោះថាក្រសួងផែនការជា ស្ថាប័នខួរក្បាលដែលគិតគូរអំពី គោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រជាតិ សម្រាប់ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រទេសជាតិទាំងមូល។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក និងសមាជិកាទាំងអស់សូមមាន សុខភាពល្អបរិបូរណ៍ទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច និងសូមទទួលបាននូវពរទាំង បួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំបាទសូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា** មេត្តាផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ មានមតិសំណេះសំណាល និងថ្លែងនូវសុន្ទរកថាបិទ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងផែនការ។

**សូមគោរពអញ្ជើញសម្តេច!**